# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ករត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់លក្ខខ័ណ្ឌ និងលក្ខណៈវិនិច្ឆ័យចាំបាច់សំរាប់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យអំពីការបង្កើតសាកលវិទ្យាល័យ ។

## ជំពូកទី ២
## និយមន័យ លក្ខណៈទូទៅ និងវិធានបង្កើត

**មាត្រា ២.-**

សាកលវិទ្យាល័យជាស្ថាប័ន ដែលមានបេសកកម្មផ្តល់ការអប់រំបណ្តុះបណ្តាលធនធានមនុស្សចាប់ពីកំរិតបរិញ្ញាប័ត្រឡើងទៅ ធ្វើការស្រាវជ្រាវ និងធ្វើសហប្រតិបត្តិការជាតិ-អន្តរជាតិ លើគ្រប់វិស័យ ដូចជា វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ដើម្បីចូលរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និង ចូលរួមចំណែកលើកស្ទួយវប្បធម៌ជាតិ និងរក្សាអត្តសញ្ញាណជាតិ ។

**មាត្រា ៣.-**

សំណុំឯកសារសុំបង្កើតសាកលវិទ្យាល័យត្រូវដាក់ជូនក្រសួងអប់រំ យុវជន និងកីឡា ។ សំណុំឯកសារទាំងនោះរួមមាន :

- ផែនការយុទ្ធសាស្ត្រ សំរាប់ការអភិវឌ្ឍន៍គ្រឹះស្ថានឧត្តមសិក្សាសាមី និងដើម្បីរួមចំណែកលើកស្ទួយវិស័យឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជា ។
- កម្មវិធីសិក្សាលំអិត រួមមានខ្លឹមសារ និងការរៀបចំ នៃកម្មវិធីសិក្សានោះ ។
- ការរៀបចំអភិបាលកិច្ចលំអិត រួមមានសមាជិកភាព និងវិធានការក្នុងការជ្រើសតាំងក្រុមប្រឹក្សាភិបាល ដើម្បីធានាអោយសមាជិកក្រុមប្រឹក្សាភិបាលមានតំណាង មកពីស្រទាប់សង្គមស៊ីវិល ។
- លក្ខខ័ណ្ឌ និងវិធានការក្នុងការជ្រើសតាំងសាកលវិទ្យាធិការ ។
- វិធានការរៀបចំសំរាប់ការគ្រប់គ្រងដ៏ត្រឹមត្រូវ ទៅលើទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ។
- សំណុំឯកសារលំអិតផ្សេងទៀត ដែលទាមទារដោយក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិនិត្យ និងវាយតំលៃ លើសំណុំឯកសារសុំបង្កើត ដើម្បីកំណត់នូវប្រភេទនៃគ្រឹះស្ថានឧត្តមសិក្សាអោយបានច្បាស់លាស់ ។ គ្រឹះស្ថានឧត្តមសិក្សា ដែលចេញសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានពីរប្រភេទគឺ : សាកលវិទ្យាល័យ និង វិទ្យាស្ថាន ។

**មាត្រា ៥.-**

សាកលវិទ្យាល័យត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដូចតទៅ :

- ផ្តល់កម្មវិធីសិក្សាពហុជំនាញ ចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅ តាមរយៈមហាវិទ្យាល័យច្រើន
- ផ្តល់កម្មវិធីសិក្សា សំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដើម្បីចេញវិញ្ញាបនប័ត្រ នៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- ផ្តល់ការបង្រៀន ចំណេះដឹង និងការស្រាវជ្រាវ ដែលជាវិធានការក្នុងការលើកកំពស់ការយល់ដឹងរបស់និស្សិត និងបំផុសនូវចំណោទបញ្ហា និងការដោះស្រាយប្រកបដោយគតិបណ្ឌិត តាមវិធីសាស្ត្រទំនើប
- មានសាស្ត្រាចារ្យ ប្រកបដោយសមត្ថភាព និងបទពិសោធន៍
- មានបណ្ណាល័យ បន្ទប់ពិសោធន៍ សៀវភៅសិក្សា និងសំភារៈរូបវ័ន្តសមស្រប សំរាប់បំរើអោយការសិក្សានិងការស្រាវជ្រាវ
- មានទីតាំង អាគារ និងបន្ទប់រៀនសមស្របតាមនិយាមគរុកោសល្យ ។

**មាត្រា ៦.-**

រចនាសម្ព័ន្ធអប់រំ នៃសាកលវិទ្យាល័យមួយ គឺជាការប្រមូលផ្តុំនូវមហាវិទ្យាល័យច្រើន និងដេប៉ាតឺម៉ង់នានាសំរាប់ផ្តល់ការអប់រំ ចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅ ដែលមានរយៈពេលសិក្សាយ៉ាងតិចបីឆ្នាំ រឺច្រើនជាង ។
រចនាសម្ព័ន្ធនេះរួមមាន :

- មហាវិទ្យាល័យ គឺជាអង្គភាពអប់រំមួយ ដែលផ្តល់នូវកម្មវិធីអប់រំ ចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅនៅក្នុងមុខជំនាញច្រើន ដែលពាក់ព័ន្ធទៅនឹងផ្នែកឯកទេសផ្សេងៗ ។
- ដេប៉ាតឺម៉ង់ គឺជាអង្គភាពអប់រំមួយស្ថិតនៅក្នុងមហាវិទ្យាល័យ ដែលផ្តល់នូវកម្មវិធីអប់រំជាក់លាក់មួយ រឺមុខជំនាញមួយ ។

**មាត្រា ៧.-**

សាកលវិទ្យាល័យត្រូវមានមហាវិទ្យាល័យបីដូចខាងក្រោម :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម

និងយ៉ាងតិចត្រូវមានមហាវិទ្យាល័យបន្ថែមពីរផ្សេងទៀត ដែលផ្តល់នូវផ្នែកឯកទេសដូចខាងក្រោម :

- វិទ្យាសាស្ត្រសុខាភិបាល
- វិស្វកម្ម និងវិទ្យាសាស្ត្រកុំព្យូទ័រ

- នីតិសាស្ត្រ
- កសិកម្ម
- ស្ថាបត្យកម្ម និងរចនាប្លង់
- ការអប់រំ
- ការគ្រប់គ្រងពាណិជ្ជកម្ម
- ទូរគមនាគមន៍ (រាប់ទាំងការសិក្សាបណ្ដុញពត៌មាន )
- ការសិក្សាអំពីបរិស្ថាន
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

វិស័យឯកទេសបន្ថែមផ្សេងៗទៀត ដែលអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

មុខជំនាញខាងក្រោមនេះត្រូវបានរាប់បញ្ចូលទៅក្នុងមហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា :

- អក្សរសាស្ត្រ
- ប្រវត្តិសាស្ត្រ
- ទស្សនវិជ្ជា
- វិចិត្រសិល្បៈ
- តូរ្យតន្ត្រី
- បុរាណវិទ្យា
- ការសិក្សាអំពីសាសនា
- ខេមរសិក្សា
- ភាសាខ្មែរ
- ភាសាអង់គ្លេស
- ភាសាបារាំង
- ភាសាផ្សេងៗទៀត

មុខជំនាញខាងក្រោមនេះត្រូវបានរាប់បញ្ចូលទៅក្នុងមហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ :

- គណិតវិទ្យា
- គីមីវិទ្យា
- ជីវវិទ្យា
- រូបវិទ្យា
- ភូគព្ភសាស្ត្រ
- វិទ្យាសាស្ត្របរិស្ថាន
- វិទ្យាសាស្ត្រអនុវត្តន៍
- កុំព្យូទ័រវិទ្យា ។ល។

មុខជំនាញខាងក្រោមនេះ ត្រូវបានរាប់បញ្ចូលទៅក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម :

- វិទ្យាសាស្ត្រនយោបាយ
- រដ្ឋបាលសាធារណៈ
- សង្គមវិទ្យា និង នរវិទ្យា
- ចិត្តវិទ្យា
- សេដ្ឋកិច្ចវិទ្យា
- ភូមិវិទ្យា
- ប្រជាសាស្ត្រ ។ល។

មុខជំនាញនីមួយៗដែលមានចែងក្នុងមាត្រាខាងលើ បង្កើតបានជាមូលដ្ឋានគ្រឹះសំរាប់បង្កើត ដេប៉ាតឺម៉ង់មួយ រឺច្រើន ។ ការបន្ថែមមុខជំនាញផ្សេងៗទៀតលើមុខជំនាញខាងលើ ត្រូវមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩.-**

វិទ្យាស្ថានត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដូចតទៅ :

- ផ្តល់ការអប់រំ ,និងគុណវុឌ្ឍិចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើងទៅ តាមរយៈការបញ្ចូលគ្នានូវផ្នែកឯកទេសមួយ ឬច្រើន ដែលស្រង់ចេញពីបញ្ជីផ្នែកឯកទេសខាងក្រោម
- ផ្តល់ការបង្រៀន ចំណេះដឹង និងការស្រាវជ្រាវដែលលើកកំពស់ ការយល់ដឹងរបស់និស្សិត និងបំផុសនូវចំណោទបញ្ហា និងការដោះស្រាយប្រកបដោយគតិបណ្ឌិតតាមវិធីសាស្ត្រទំនើប

- មានសាស្ត្រាចារ្យ ប្រកបដោយសមត្ថភាព និងបទពិសោធន៍
- មានបណ្ណាល័យ បន្ទប់ពិសោធន៍ សៀវភៅសិក្សា និងសំភារៈរូបវ័ន្តសមស្រប សំរាប់បំរើអោយការសិក្សា និងការស្រាវជ្រាវ
- មានទីតាំងអាគារ និងបន្ទប់រៀនសមស្រប តាមនិយាមគរុកោសល្យ ។

មាត្រា ១០.-

វិទ្យាស្ថានអាចផ្តល់នូវកម្មវិធីអប់រំសំរាប់សញ្ញាប័ត្រ និងគុណវុឌ្ឍិ នូវផ្នែកឯកទេសដូចខាងក្រោម :

- វិទ្យាសាស្ត្រសុខាភិបាល
- វិស្វកម្ម និងវិទ្យាសាស្ត្រកុំព្យូទ័រ
- នីតិសាស្ត្រ
- កសិកម្ម
- ស្ថាបត្យកម្ម និងរចនាប្លង់
- អប់រំ
- ការគ្រប់គ្រងពាណិជ្ជកម្ម
- ទូរគមនាគមន៍ ( រាប់ទាំងការសិក្សាបណ្តាញពត៌មាន )
- ការសិក្សាអំពីបរិស្ថាន
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

រឺមុខជំនាញផ្សេងៗទៀត ដែលអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១១.-

ការបង្កើតសាកលវិទ្យាល័យរដ្ឋជាកម្មវត្ថុ នៃអនុក្រឹត្យបង្កើត រីឯការបង្កើតសាកលវិទ្យាល័យឯកជនជាកម្មវត្ថុនៃអនុក្រឹត្យទទួលស្គាល់ ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំលក្ខខ័ណ្ឌ និងលក្ខណៈវិនិច្ឆ័យលំអិតសំរាប់ការបង្កើតសាកលវិទ្យាល័យ និងមានភារៈកិច្ចពិនិត្យ សំណុំឯកសារសុំបង្កើតសាកលវិទ្យាល័យ ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសំរេច ។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ១២.-**

សាកលវិទ្យាល័យដែលកំពុងដំណើរការសព្វថ្ងៃ មានរយៈពេល ១០ ឆ្នាំ ( ដប់ឆ្នាំ ) ដើម្បីរៀបចំកែលំអ អោយបានស្របទៅនិងលក្ខណៈវិនិច្ឆ័យដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ។

**មាត្រា ១៣.-**

សាកលវិទ្យាល័យដែលកំពុងដាក់ពាក្យសុំថ្មី មានរយៈពេល ០៣ ឆ្នាំ ( បីឆ្នាំ ) ដើម្បីរៀបចំកែលំអ អោយបានស្របទៅ និងលក្ខណៈវិនិច្ឆ័យដូចបានកំណត់ក្នុងអនុក្រឹត្យនេះ បន្ទាប់ពីបានទទួលការយល់ព្រមរួចហើយពីរាជរដ្ឋាភិបាល ។

បើមានមូលហេតុសមស្របរយៈពេលរៀបចំកែលំអនេះ អាចពន្យាពេលបាន ០៣ ( បី ) ឆ្នាំទៀត ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធិភាព ។

**មាត្រា ១៥.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- ឯកសារ-កាលប្បវត្តិ